# កត្តាចំបងដែលជម្រុញឱ្យមានការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយក្នុងចំណោមទារកទើបកើត នៅតាមមូលដ្ឋានសុខាភិបាលនៅទីប្រជុំជនក្នុងប្រទេសកម្ពុជានិងប្រទេសនេប៉ាល់

សូមទាញយកអត្ថបទពីគេហទំព័រ: https://onlinelibrary.wiley.com/doi/full/10.1111/mcn.12754

សេចក្តីសង្ខេប


ការណែនាំប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយក្នុងអំឡុងម៉ោងដំបូងក្រោយសម្រាលអាចបង្កើននូវបម្រែបម្រួលរបស់ទារក និងរួមចំណែកដល់ការថយចុះរយៈពេលនៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ។ ការសិក្សានេះបានវាយតម្លៃពីកត្តាសំខាន់ៗដែលជម្រុញឱ្យមានការប្រើប្រាស់ផលិតផលជំនួសទឹកដោះ ម្តាយក្នុងចំណោមទារកទើបកើតនៅមូលដ្ឋានសុខាភិបាលក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា និងទីក្រុងខាត់ម៉ាន់ឌូវលើយ៍នៃប្រទេសនេប៉ាល់។ ការអង្កេតក្នុងរយៈពេលជាក់លាក់មួយត្រូវបានធ្វើឡើងក្នុងចំណោមម្តាយៗចំនួន៣០៩នាក់ក្នុងទីក្រុងខាត់ម៉ាន់ឌូវលើយ៍ និងម្តាយចំនួន៣០៦នាក់នៅក្នុងរាជធានីភ្នំពេញបន្ទាប់ពីចាកចេញពីមូលដ្ឋានសុខាភិបាលក្រោយពីសម្រាលកូនរួច។ដោយផ្អែកលើការយល់ឃើញនិងទំលាប់ជាទូទៅរបស់ប្រជាជនក្នុងការផ្តល់បន្ថែមនូវសារធាតុរាវ/អាហារផ្សេងៗដល់ទារកមុនពេលឱ្យបៅទឹកដោះម្តាយ ការវិភាគលើកត្តាពាក់ព័ន្ធសំខាន់ៗជាច្រើនត្រូវបានប្រើប្រាស់ដើម្បីកំណត់កត្តាចំបងៗអ្វីខ្លះដែលជម្រុញឱ្យមានការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយមុនពេលម្តាយៗបានចាកចេញពីមូលដ្ឋានសុខាភិបាល។

ច្រើនជាងពាក់កណ្តាលនៃម្តាយៗ បានចិញ្ចឹមកូនដោយផលិតផលជំនួសទឹកដោះម្តាយ ដោយក្នុងនោះមានចំនួន៥៦,៩%នៅរាជធានីភ្នំពេញនិង៥៥,៩%ទីក្រុងខាត់ម៉ាន់ឌូវលើយ៍។ ការចិញ្ចឹមទារកដោយផលិតផលជំនួសទឹកដោះម្តាយគឺមានការកើនឡើងនៅរាជធានីភ្នំពេញនិងទីក្រុងខាត់ម៉ាន់ឌូវលើយ៍ ដោយសារអ្នកផ្តល់សេវាសុខាភិបាលបានផ្តល់យោបល់ឱ្យប្រើប្រាស់ផលិតផលទាំងនោះក្នុងនោះ អត្រា (odds ratio: 24.87; confidence interval [6.05, 102.29]; odds ratio: 2.42; CI [1.20, 4.91]។ នៅទីក្រុងខាត់ម៉ាន់ឌូវលើយ៍ ការផ្តល់យោបល់របស់មិត្តភក្តិ និងសមាជិកក្រុមគ្រួសារ និងការសម្រាលកូនដោយវះកាត់ គឺជាមូលហេតុជម្រុញឱ្យម្តាយៗសម្រេចចិត្តប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយ។ សិទ្ធិក្នុងការបំបៅកូនដោយទឹកដោះម្តាយនៅក្នុងអំឡុងម៉ោងដំបូងរបស់ទារកត្រូវបានការពារនិងលើកកម្ពស់ ដើម្បីប្រឆាំងនឹងការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយនៅទីក្រុងខាត់ម៉ាន់ឌូវលើយ៍។ ការគាំទ្រនិងលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយពីអ្នកផ្តល់សេវាសុខាភិបាលនឹងកាត់បន្ថយ

ការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្ដាយសម្រាប់ចិញ្ចឹមទារកដែលទើបកើត។ ការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្ដាយនៅក្រៅមូលដ្ឋានសុខាភិបាល គឺមានការកើនឡើងខ្លាំងក្នុងរាជធានីភ្នំពេញ (៨៤,៦%) និងទីក្រុងខាត់ម៉ាន់ឌូវរលីយ៍  (២៧%) ប៉ុន្តែទោះយ៉ាងណាក៏ដោយ វាមិនមែនជាមូលហេតុចំបងដែលជម្រុញឱ្យមានការចិញ្ចឹមទារកទើបកើតដោយផលិតផលជំនួសទឹកដោះម្ដាយនោះឡើយ។ ការអនុវត្តដោយជោគ ជ័យលើការលើកកម្ពស់ និងជម្រុញការបំបៅកូនដោយទឹកដោះម្ដាយគួរតែត្រូវបានធ្វើឡើងជាអាទិភាពមុនពេល ម្ដាយៗចាកចេញពីមូលដ្ឋានសុខាភិបាលក្រោយពេលសម្រាលរួច ហើយអ្នកផ្ដល់សេវាសុខាភិបាលគួរតែផ្ដល់និងគាំទ្រជម្រុញលើកទឹកចិត្តការបំបៅកូនដោយទឹកដោះម្ដាយក្នុងចំណោមម្ដាយថ្មីៗទាំងអស់។